**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ការអញ្ជើញឲ្យដាក់សំណើដេញថ្លៃ

**ការអញ្ជើញលេខ:** CDRR/SRP-ROAD-1704

**លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន**

**សមាសភាព** C

មូលនិធិលេខ: 9178-CAM

មានបំណងជ្រើសរើសអ្នកទទួលការ ដើម្បីអនុវត្តការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចខាងក្រោម៖
ឈ្មោះកិច្ចសន្យា៖ ជួសជុលផ្លូវ ក្រាលក្រួសធម្មជាតិ ប្រវែង២៥៥០ម៉ែត្រ ទទឹងផ្លូវ៥ម៉ែត្រ ស្ថិតនៅភូមិថ្នល់លោក ឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប។

១. រាជរដ្ឋាភិបាលកម្ពុជាបានទទួលជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការចំណាយលើគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន ហើយមានបំណងប្រើប្រាស់មួយផ្នែកនៃជំនួយឥតសំណងនេះសម្រាប់ចំណាយលើកិច្ចសន្យា ជួសជុលផ្លូវ ក្រាលក្រួសធម្មជាតិ ប្រវែង២៥៥០ម៉ែត្រ ទទឹងផ្លូវ៥ម៉ែត្រ (CDRR/SRP-ROAD-1704)។

២. តម្លៃប៉ាន់ស្មានសម្រាប់កិច្ចសន្យានេះគឺ ៣០.៦៩០,00ដុល្លារសហរដ្ឋអាមេរិក (សាមសិបពាន់ប្រាំមួយរយកៅសិប ដុល្លារអាមេរិក)។

៣. កាលវិភាគសាងសង់មានរយៈពេល ០២ខែ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្ដើម

៤. អ្នកទទួលការមានសិទ្ធិ និងលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលមានចំណាប់អារម្មណ៍ ត្រូវបានអញ្ជើញឲ្យមកទទួលយកឯកសារដេញថ្លៃចំនួនមួយច្បាប់ដោយឥតគិតថ្លៃ នៅអាសយដ្ឋានខាងក្រោម។

៥. ដើម្បីក្លាយជាអ្នកដែលមានសិទ្ធិ អ្នកទទួលការត្រូវ ៖
   ក. បានចុះបញ្ជីការស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
   ខ. មិនឋិតនៅក្រោមការហាមឃាត់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ឬធនាគារអភិវឌ្ឍន៍អាស៊ី។

៦. ដើម្បីចាត់ទុកជាអ្នកដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ អ្នកទទួលការត្រូវ ៖
   ក. ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ ធ្លាប់បានបញ្ចប់កិច្ចសន្យាយ៉ាងតិចចំនួន២ នៃប្រភេទការងារប្រហាក់ប្រហែលគ្នាដែលកិច្ចសន្យានិមួយៗមានតម្លៃយ៉ាងតិច ៧៥%នៃតម្លៃដាក់ដេញថ្លៃ។
   ខ. រយៈពេល២ឆ្នាំចុងក្រោយអ្នកម៉ៅការត្រូវមានផលរបរសរុបប្រចាំឆ្នាំចំនួនយ៉ាងតិច១.៥ដងនៃតម្លៃដាក់ដេញថ្លៃ។

គ. អ្នកគ្រប់គ្រងសំណង់ដែលស្នើមក ត្រូវមានបទពិសោធន៍យ៉ាងតិច ៣ឆ្នាំ ក្នុងការត្រួតពិនិត្យការងារដែលមានលក្ខណៈប្រហាក់ប្រហែល និងធ្លាប់មានតួនាទីជាអ្នកគ្រប់គ្រងការងារសំណង់ក្នុងរយៈពេលមិនតិចជាង១ឆ្នាំ។

ឯកសារដែលជាភស្តុតាងបង្ហាញអំពីលក្ខណសម្បត្តិរបស់អ្នកដេញថ្លៃត្រូវដាក់ភ្ជាប់មកជាមួយសំណើដេញថ្លៃ។

៧. សំណើដេញថ្លៃទាំងអស់ត្រូវដាក់មកអាស័យដ្ឋានខាងក្រោមនៅត្រឹមឬមុន ម៉ោង ៩:៣០នាទីព្រឹក ថ្ងៃទី១១ ខែកក្កដា ២០១៧។ សំណើដេញថ្លៃណាដែលដាក់មកយឺត នឹងត្រូវបានបដិសេធចោល។ សំណើដេញថ្លៃដែលបានទទួលនឹងត្រូវបានបើកជាសាធាណៈភ្លាមៗ ក្រោយកាលបរិច្ឆេទផុតកំណត់នៅអាស័យដ្ឋានដដែល ដោយមានវត្តមានតំណាងអ្នកដេញថ្លៃទាំងអស់ ហើយអ្នកទទួលផលគម្រោងពីសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធដែលមានបំណងចង់ចូលរួម ត្រូវបានអនុញ្ញាតឲ្យចូលរួមដោយផ្ទាល់ ។ អាសយដ្ឋានសម្រាប់ដាក់សំណើដេញថ្លៃ និងបើកសំណើដេញថ្លៃ គឺ៖

អាសយដ្ឋាន៖ សាលាស្រុកជីក្រែង ស្ថិតក្នុងភូមិកំពង់ក្តី២ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប

បន្ទប់៖ បន្ទប់ប្រជុំក្រុមប្រឹក្សា នៃសាលាស្រុកជីក្រែង

៨. ម្ចាស់គម្រោងនឹងផ្តល់កិច្ចសន្យាដល់អ្នកដេញថ្លៃណា ដែលត្រូវបានពិនិត្យឃើញថា សំណើដេញថ្លៃមានតម្លៃទាបជាងគេបំផុត នឹងឆ្លើយតបទាំងស្រុងទៅតាមលក្ខខណ្ឌតម្រូវនានានៃឯកសារដេញថ្លៃ ហើយអ្នកដេញថ្លៃនោះមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យាដោយការពេញចិត្ត។

៩. សំណើដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវលិខិតប្រកាសស្តីពីការធានាសំណើដេញថ្លៃ និងការអនុវត្តន៍កិច្ចសន្យា (bid and performance securing declaration) ដូចបានរៀបរាប់ក្នុងសេចក្តីណែនាំសម្រាប់អ្នកដេញថ្លៃ (Instructions to Bidders) ។ ចំពោះសំណើដេញថ្លៃណាដែលមិនបានភ្ជាប់មកនូវលិខិតប្រកាសស្តីពីការធានាសំណើរដេញថ្លៃ និងការអនុវត្តន៍កិច្ចសន្យានេះ នឹងត្រូវ បដិសេធន៍ចោលដោយចាត់ទុកថាមិនបានឆ្លើយតបតាមលក្ខខណ្ឌតម្រូវ។

១០. អាសយដ្ឋានដើម្បីសាកសួរព័ត៌មាន និងទទួលយកឯកសារដេញថ្លៃគឺ៖

លោក អ៊ឹង ធី

អាសយដ្ឋាន៖ សាលាស្រុកជីក្រែង ស្ថិតក្នុងភូមិកំពង់ក្តី២ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប

អ៊ីម៉ែល៖ ungthytsprsdp@gmail.com

លេខទូរសព្ទ៖ ០៨៩ ៩៤៧ ៧៣៥

ម៉ោងការងារ ព្រឹក៖ ៨.៣០ ដល់ ១១.៣០ , ល្ងាច៖ ២.៣០ដល់៤.៣០

១១. ក្នុងករណីដែលមានការលំបាកក្នុងការទទួលឯកសារដេញថ្លៃ ភាគីទាំងឡាយដែលមានចំណាប់អារម្មណ៍អាចទាក់ទងជាលាយលក្ខណ៍អក្សរមក ៖

ឯកឧត្តម នី គឹមសាន, ប្រធានគម្រោង លេខាធិការ ដ្ឋាន គ.ជ.អ.ប

អាសយដ្ឋាន៖ មហាវិថីនរោត្តម ចំការមន ភ្នំពេញ
លេខទូរសព្ទ៖ ០១១ ៩៧០ ៥៦៥
អ៊ីម៉ែល៖ kimsanny1973@gmail.com
និងផ្ញើឯកសារដែល ទំនាក់ទំនងនោះមួយច្បាប់ផងដែរទៅលោក **យី សុខធារិទ្ធ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, ភ្នំពេញ, កម្ពុជា លេខទូរសព្ទ៖ (៨៥៥) ២៣ ៧២៤ ៦៦៤ លេខទូរសព្ទដៃ៖ (៨៥៥) ១២ ៥៨៥ ៩៥៩ អ៊ីម៉ែល៖ sokthearith_yi@mef.gov.kh

១២. រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី នឹងប្រកាសរៀងៗខ្លួនអំពីការដកសិទ្ធិទាំងស្រុងពីក្រុមហ៊ុនដោយមិនកំណត់ពេល ឬក្នុងរយៈពេលកំណត់ណាមួយ ពីការទទួលបានកិច្ចសន្យា ដែលប្រើប្រាស់មូលនិធិរាជរដ្ឋាភិបាលកម្ពុជា និងធានាគារអភិវឌ្ឍន៍អាស៊ី ប្រសិនបើនៅពេលណាមួយដែលពិនិត្យឃើញថាក្រុមហ៊ុននោះជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ឬអំពើកេងបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំក្នុងការប្រកួតប្រជែងដើម្បីទទួលបានកិច្ចសន្យា ឬក្នុងពេលអនុវត្តកិច្ចសន្យា។

១៣. ភាគីពាក់ព័ន្ធ អាចប្ដឹងតវ៉ានៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការលទ្ធកម្ម។ នីតិវិធីនៃការប្ដឹងតវ៉ាបានរៀបរាប់ក្នុង ប្រការ២១ នៃសេចក្ដីណែនាំសម្រាប់អ្នកដេញថ្លៃ ។

យើងខ្ញុំរង់ចាំទទួលសំណើដេញថ្លៃពេញលេញ និងឆ្លើយតបតាមលក្ខខណ្ឌតម្រូវ មុនកាលបរិច្ឆេទផុតកំណត់ដែលបានបញ្ជាក់ខាងលើ និងតាមលក្ខខណ្ឌដែលបានរៀបរាប់ក្នុងឯកសារដេញថ្លៃដោយសេចក្ដីរាប់អាន។

សាលាស្រុកជីក្រែង ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៧
អភិបាលស្រុក

ទោរ ប៊ុនធឿន